**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍

## ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

### ១-គោលបំណង

គោលបំណងនៃកិច្ចប្រជុំមាន បញ្ចប់ការពិនិត្យលើពង្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៥ និងការកែសម្រួលសេចក្តីសម្រេចនៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ និងពិនិត្យលើអនុសាសន៍នៃកិច្ចប្រជុំប្រចាំត្រីមាស។

តាមរយៈនៃកិច្ចប្រជុំ សមាជិកក្រុមការងារទាំងអស់រំពឹងថា នឹងបានរបាយការណ៍ និងការកែសម្រួលសេចក្តីសម្រេចនៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

### ២-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន

កាលបរិច្ឆេទ: ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦

ទីកន្លែង : នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

វត្តមាន : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ MHC, MHSS,SIT,RHAC,BC,PSK, PSC, FHI360,AHF,Khemara,and MEC.

### ៣-វិធីសាស្រ្ត : ពិភាក្សារួម

### ៤-លទ្ធផល

នៅថ្ងៃពុធ ទី១១ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំនូវកិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការដឹកនាំប្រជុំដោយ លោកវេជ្ជ. រ៉ឹង យ៉ាណាត ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។ ជាកិច្ចចាប់ផ្តើម លោកប្រធានកិច្ចប្រជុំ បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារលេខាធិការ ដែលបានចូលរួមប្រជុំនាពេលនេះ ព្រមទាំងពិនិត្យពិភាក្សាលំអិតលើរបៀបវារៈនីមួយៗដែលបានគ្រោងទុក ដោយសម្រេចលទ្ធផលដូចខាងក្រោម៖

១. បញ្ចប់ពិនិត្យលើពង្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៥ នៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍:

សមាជិកក្រុមការងារបានពិនិត្យ និងកែសម្រួលសម្រេចលើរបាយការណ៍ប្រចាំឆ្នាំ២០១៥ និងដាក់ជូនប្រធានក្រុមការងារពិនិត្យ និងសម្រេច។

២. ការកែសម្រួលសមាជិកភាពនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដោយសម្រេចដូចខាងក្រោម:

១.ការបង្កើតក្រុមប្រឹក្សាភិបាលនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

២.កែសម្រួលសមាជិកភាពនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ និងក្រុមការងារលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ មានភ្ជាប់ពង្រាងសេចក្តីសម្រេចនៅខាងក្រោយ។

៣.របៀបវារៈនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដោយសម្រេចដូចខាងក្រោម:

៣.១ ការបង្ហាញពីរបាយការណ៍ប្រចាំឆ្នាំ២០១៥ នៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដោយលោកផល សុផាត សមាជិកក្រុមការលេខាធិការដ្ឋាន។

៣.២ ការបង្ហាញពីបញ្ហាប្រឈមនានាដែលបានជួបក្នុងឆ្នាំ២០១៥ និងដំណោះស្រាយដើម្បីរៀបចំជាផែនការសកម្មភាពសំរាប់អនុវត្តឆ្នាំ២០១៦ដោយលោកដោក បញ្ញា សមាជិកក្រុមការលេខាធិការដ្ឋាន។

៣.៣ ការបង្ហាញពីការផ្តល់សេវាពិនិត្យសុខភាពដោយអង្គការMEC ដោយលោកកេត ថារិទ្ធ សមាជិកក្រុមការលេខាធិការដ្ឋាន។

៣.៤ ការបង្ហាញពីការផ្តល់សេវាពិនិត្យសុខភាពដោយអង្គការPSC ដោយលោកកែវ ចំណាន សមាជិកក្រុមការលេខាធិការដ្ឋាន។

## ៥-សំណូមពរ និងអនុសាសន៍

១. ស្នើរសមាជិកលេខាធិការដ្ឋានជួយពិនិត្យ បំពេញ និងកែសម្រួលលើពង្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៥ នៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ និងការកែសម្រួលសមាជិកភាព នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ឲ្យបានមុនថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ជាកំហិត។

២.ស្នើរអោយសមាជិកលេខាធិការដ្ឋានជាមួយការទទួលខុសត្រូវនូវភារៈកិច្ចរបស់ខ្លួន ក៏ត្រូវមានការតាំងចិត្ត និងចំណាយពេលវេលាក្នុងការចូលរួមអោយបានសកម្មក្នុងក្រុមការងារលេខាធិការដ្ឋានក៏ដូចជាក្រុមការងារបច្ចេកទេសផងដែរ។

៣. ស្នើរសមាជិកលេខាធិការដ្ឋាន ពិសេសមន្ត្រីដែលជាអ្នកសម្របសម្រួល ធ្វើលិខិតជាផ្លូវការដើម្បីដាក់បញ្ចូលឈ្មោះទៅក្នុងក្រុមការងារ។

**៦-ការងារដែលត្រូវធ្វើបន្ត**

១.ក្រុមការងារលេខាធិការដ្ឋាន នឹងរៀបចំកិច្ចប្រជុំប្រចាំខែមេសា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២.រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ។

៣.រៀបចំកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ក្រោមជាតិស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ នៅខេត្តសៀមរាប។/

ភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦

អ្នកធ្វើរបាយការណ៍

បានឃើញ និងពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋាន

បានឃើញ និងឯកភាព

អគ្គលេខាធិការ